# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួល ទទួល គ្រប់គ្រង និងចាត់ចែងរថយន្ត ដែលជាអំណោយរបស់ក្រុមហ៊ុន ប៊ូ យ៉ុង គ្រុប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួល ទទួល គ្រប់គ្រង និងចាត់ចែងរថយន្ត ដែលជាអំណោយរបស់ក្រុមហ៊ុន ប៊ូ យ៉ុង គ្រុប ហៅកាត់ថា "**ក្រុមការងារអន្តរក្រសួង**" ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិត **ជូ គីមឡេង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ) | ប្រធាន |
| ២-ឯកឧត្តម **លេង ទី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម **ប៉ែន ធីរុត្ថ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ | អនុប្រធាន |
| ៤-ឯកឧត្តម **នុប សុធនវិចិត្រ** | អនុរដ្ឋលេខាធិការ និងជានាយករងខុទ្ទកាល័យ ក.ស.ហ.វ | សមាជិក |
| ៥- ឯកឧត្តម **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក.ស.ហ.វ | សមាជិក និងជាប្រធានលេខាធិការដ្ឋាន |
| ៦- ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ | សមាជិក |
| ៧- ឯកឧត្តម **សួស ប្រាថ្នា** | អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តម **កើត ឆែ** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៩- ឯកឧត្តមបណ្ឌិត **គឹម កែវមុនីរ័ត្ន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា ក.ស.ហ.វ | សមាជិក |
| ១០-ឯកឧត្តម **ហ៊ីង ច័ន្ទបូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក.ស.ហ.វ | សមាជិក |
| ១១-ឯកឧត្តម **សឿក សុភ័គ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក.ស.ហ.វ | សមាជិក |
| ១២-លោក **សារឿន សុកុល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក.ស.ហ.វ | សមាជិក |
| ១៣-លោក **ម៉ៅ យុទ្ធថា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក.ស.ហ.វ | សមាជិក |
| ១៤-ឧត្តមសេនីយ៍ទោ **មាឡា សុវណ្ណារដ្ឋ** | នាយក នាយកដ្ឋានយានយន្ត នៃអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ | សមាជិក |
| ១៥-លោក **ម៉ុន ជីវ** | ប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ | សមាជិក |

| | | |
|---|---|---|
| ១៦-លោក **ណាំ ស៊ីនិត** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក.ស.ហ.វ | លេខាធិការ |
| ១៧-លោក **ផាន់ មករា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក.ស.ហ.វ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួង ដូចមានចែងក្នុងប្រការ ១ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យរៀបចំអនុស្សរណៈ នៃការយោគយល់ (MoU) រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតំណាង ជាមួយក្រុមហ៊ុនប៊ូ យ៉ុង គ្រុប នៃសាធារណៈរដ្ឋកូរ៉េ
- ពិនិត្យ ពិភាក្សា អំពីនីតិវិធី និងកាតព្វកិច្ចរបស់ភាគីទាំងពីរ ក្នុងការរៀបចំទិញរថយន្តពីក្រុមហ៊ុនលក់ ឬក្រុមហ៊ុនផលិតរថយន្ត ដែលមានទីតាំងនៅប្រទេសចិន និង ការដឹកជញ្ជូនពេលរថយន្តមកដល់ព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងសម្របសម្រួលបែបបទ និងនីតិវិធីនាំចូលរថយន្ត ដោយដាក់ពន្ធគយ និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ
- ពិនិត្យ ពិភាក្សា និងសម្របសម្រួលអំពីការដឹកជញ្ជូន និងទីតាំងដែលត្រូវប្រគល់ និងទទួលទំនិញ
- រៀបចំផែនការសម្រាប់អនុវត្តការងារ ទទួល គ្រប់គ្រង ចាត់ចែង និងបែងចែករថយន្ត បន្តជូនរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ដោយលើកសំណើរគោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគោរពស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- សហការជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ក្នុងការកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដោយរៀបចំនីតិវិធី ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីប្រសិទ្ធភាពលើយន្តការនៃការគ្រប់គ្រង ការផ្តល់សេវារថយន្តក្រុងជូនប្រជាពលរដ្ឋ និងលើការទុកដាក់ ថែទាំ និងការជួសជុលរថយន្ត ក្រោយពេលរដ្ឋបាលរាជធានី-ខេត្ត បានទទួលរថយន្តយកទៅប្រើប្រាស់
- សហការ និងសម្របសម្រួលជាមួយក្រសួងការពារជាតិ ចំពោះរថយន្តចំនួន ១០០ គ្រឿង ដែលត្រូវប្រគល់ជូនក្រសួងការពារជាតិ តាមការជាក់ស្តែង
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ គោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគោរពរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ ៣.-**

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ត្រូវចាត់តាំងអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

ក្នុងករណី អនុប្រធាន ឬសមាជិកណាម្នាក់ ពុំអាចចូលរួមកិច្ចប្រជុំបាន អនុប្រធាន ឬសមាជិកនោះ ត្រូវចាត់តំណាងរបស់ខ្លួនដើម្បីចូលរួមកិច្ចប្រជុំជំនួស។

ក្រុមការងារអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញការងារ។

**ប្រធានក្រុមការងារអន្តរក្រសួង** មានសិទ្ធិចាត់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ជាសេនាធិការរបស់ក្រុមការងារអន្តរក្រសួង ដើម្បីជាជំនួយការសម្រួលការងាររដ្ឋបាល និងការងារលេខាធិការនានា តាមការចាំបាច់។

**ប្រការ ៥.-**

**ក្រុមការងារអន្តរក្រសួង** នឹងត្រូវរំសាយវិញ ក្រោយពេលដែលគម្រោង ត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែបឋមាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ